# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.)
# គម្រោងបញ្ចប់ផែនការ
# កំណែលើកទី៣៥
# ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២


*សេចក្តីសង្ខេប*...1
I. **សេចក្តីផ្តើម**...2
II. **សំណុំរឿងដែលបានបញ្ចប់**...2
III. **សំណុំរឿងបច្ចុប្បន្ន**...4
IV. **វិធានការដែលអាចជួយបញ្ចប់កិច្ចដំណើរការនីតិវិធីបានឆាប់រហ័ស**...4
V. **សេចក្តីសន្និដ្ឋាន**...5


**កំណត់សម្គាល់សម្រាប់អ្នកអាន៖**

គម្រោងបញ្ចប់ផែនការ អ.វ.ត.ក. ត្រូវបានកែប្រែប្រចាំត្រីមាសដើម្បីគោលបំណងរៀបចំផែនការ។ វាមានការប៉ាន់ស្មានដែលល្អបំផុតដែលអាចមានសម្រាប់ការព្យាករណ៍តារាងកំណត់ពេលវេលា ក្នុងរឿងក្តីនៅចំពោះមុខ អ.វ.ត.ក. នៅពេលធ្វើកំណែ។ កត្តាមួយចំនួន រួមមានការវិវឌ្ឍនៃកិច្ចនីតិវិធីតុលាការ អាចប៉ះពាល់ការព្យារកណ៍ទាំងនេះ។ ដូច្នេះតារាងកំណត់ពេលវេលានេះមិនឆ្លុះបញ្ចាំងលក្ខខណ្ឌតម្រូវផ្នែកលក្ខន្តិកៈ ទៅលើថាតើពេលណាគ្រោងការសំខាន់ៗនឹងសម្រេចបាននោះទេ។ គម្រោងបញ្ចប់ផែនការ អ.វ.ត.ក. ត្រូវបានរៀបចំឡើង និងចេញដោយការិយាល័យរដ្ឋបាល ដោយមានព័ត៌មានពីការិយាល័យតុលាការ។

## សេចក្តីសង្ខេប

គម្រោងបញ្ចប់ផែនការសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អង្គជំនុំជម្រះវិសាមញ្ញ”) បានរៀបចំឡើងដំបូងនៅ*ខែមីនា ឆ្នាំ២០១៤* ដោយឆ្លងកាត់ការពិគ្រោះពិភាក្សាយោបល់ពីសំណាក់ការិយាល័យរដ្ឋបាល ជាមួយនឹងចៅក្រមនៃអង្គជំនុំជម្រះ សហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញា ទាក់ទិននឹងការទទួលខុសត្រូវរបស់ពួកគាត់។ នេះគឺជាបច្ចុប្បន្នភាពប្រចាំត្រីមាសទី៣៤ [៣៥] នៃគម្រោងបញ្ចប់ផែនការដែលគ្របដណ្តប់ត្រីមាសដែលផុតនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២[1]។

ក្នុងអំឡុងពេលត្រីមាសនេះ អង្គជំនុំជម្រះតុលាការកំពូលបានជូនដំណឹងអំពីសាលដីកាជាលាយលក្ខណ៍អក្សរពេញលេញ លើបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០២ ប្រឆាំងនឹង ខៀវ សំផន ហេតុដូច្នេះបានបញ្ចប់កិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខក្នុងរឿងក្តីនោះ។ អង្គជំនុំជម្រះវិសាមញ្ញបានប្តូរទីតាំងប្រតិបត្តិការរបស់ខ្លួនមកកាន់អគារមុខងារសេសសល់នៅកណ្តាលទីក្រុងភ្នំពេញ។

---

[1] គម្រោងបញ្ចប់ផែនការ និងកំណែប្រែរបស់គម្រោងនេះអាចរកបានជាសាធារណៈនៅលើ*គេហទំព័រ អ.វ.ត.ក.*។

## I. សេចក្តីផ្តើម

១. អង្គជំនុំជ្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អង្គជំនុំជម្រះវិសាមញ្ញ”) បានចាប់ផ្តើមដំណើរការរបស់ខ្លួននៅខែកុម្ភៈ ឆ្នាំ២០០៦ និងបានដំណើរការពេញលេញបន្ទាប់ពីការអនុម័តវិធានផ្ទៃក្នុងនៅក្នុងខែមិថុនា ឆ្នាំ២០០៧។ អាណត្តិនៃអង្គជំនុំជម្រះវិសាមញ្ញ គឺដើម្បីកាត់សេចក្តី “មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩”[2]។ នៅខែធ្នូ ឆ្នាំ២០២១ កិច្ចព្រមព្រៀបន្ថែមទៅនឹងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា បានចូលជាធរមាន។ កិច្ចព្រមព្រៀងបន្ថែមនេះផ្តល់ឱ្យអង្គជំនុំជម្រះវិសាមញ្ញនូវអាណត្តិមុខងារសេសសល់ ដែលនឹងចាប់ផ្តើមសម្រាប់រយៈពេលបីឆ្នាំដំបូង បន្ទាប់ពីការបញ្ចប់កិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខ។

២. គម្រោងបញ្ចប់ផែនការនេះបានបរិយាយយ៉ាងលម្អិតដោយ អ.វ.ត.ក. ក្នុងបរិបទនៃសេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ A/RES/68/247B ដែលក្នុងចំណោមបញ្ហាផ្សេងៗទៀត បានកំណត់អាណត្តិរបស់ អ.វ.ត.ក. ឱ្យរៀបចំយុទ្ធសាស្ត្របញ្ចប់ ដោយមានផែនទីបង្ហាញផ្លូវច្បាស់លាស់មួយ។ ឯកសារនេះធ្វើឡើងដោយ អ.វ.ត.ក. ដោយមានការពិគ្រោះយោបល់តាមរយៈ ការិយាល័យរដ្ឋបាលជាមួយចៅក្រមអង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល សហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញាអំពីការទទួលខុសត្រូវរបស់ពួកគេ។ អង្គជំនុំជម្រះវិសាមញ្ញធ្វើបច្ចុប្បន្នភាពផែនការបញ្ចប់នេះរៀងរាល់ត្រីមាស។ ឯកសារបច្ចុប្បន្ននេះគឺជាកំណែលើកទី៣៥ ប្រចាំត្រីមាសនៃគម្រោងបញ្ចប់ផែនការ ហើយបានបញ្ចូលនូវការកែតម្រូវដោយផ្អែកលើការវិវត្តនៃដំណើរការនីតិវិធីតាមផ្លូវតុលាការ ដែលកំពុងប្រព្រឹត្តទៅក្នុងរវាងថ្ងៃទី១ ខែតុលា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២។

៣. ឯកសារនេះផ្តល់នូវព័ត៌មានអំពីស្ថានភាពនៃរឿងក្តី នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ។ កិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២ បានបញ្ចប់ បន្ទាប់ពីការវិនិច្ឆ័យចុងក្រោយនៃសំណុំរឿង ០០២/០២[3]។ សហព្រះរាជអាជ្ញាបានថ្លែងជាសាធារណៈថា នឹងមិនមានសំណុំរឿងបន្ថែមទៀត បន្ទាប់ពីសំណុំរឿង ០០៤ នោះឡើយ[4]។ ដូច្នេះ បន្ទុករឿងក្តីបច្ចុប្បន្នគឺជាសំណុំរឿងសរុបដែលអង្គជំនុំជម្រះវិសាមញ្ញត្រូវដោះស្រាយ។

## II. សំណុំរឿងដែលបានបញ្ចប់[5]

៤. សំណុំរឿង០០១ ប្រឆាំងនឹង កាំង ហ្កេកអ៊ាវ (ហៅ ឌុច) គឺជាសំណុំរឿងដំបូងដែលបានជំនុំជម្រះនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ។ នៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ អង្គជំនុំជម្រះតុលាការកំពូល បានប្រកាសសាលដីការបស់ខ្លួននៅក្នុងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ធ្វើឲ្យ

---

[2] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ។

[3] នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៧ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចដែលសម្រេចបញ្ចប់កិច្ចដំណើរការនីតិវិធីពាក់ព័ន្ធនឹងអង្គហេតុនានាដែលបានរៀបរាប់នៅក្នុងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ ដែលមិនត្រូវបានបញ្ចូលទៅក្នុងសំណុំរឿង ០០២/០១ ឬសំណុំរឿង ០០២/០២៖ សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសង (*ឯកសារ E439/5*)។

[4] *សេចក្តីប្រកាសព័ត៌មានរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី - ការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរថ្មីចំនួនពីរ ថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០០៩។ សេចក្តីប្រកាសព័ត៌មានរបស់សហព្រះរាជអាជ្ញាទាក់ទិននឹងការស៊ើបអង្កេតនៅក្នុងសំណុំរឿង០០៣ ថ្ងៃទី៥ ខែមិថុនា ឆ្នាំ ២០១២ និងសេចក្តីប្រកាសព័ត៌មានរបស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទិននឹងចំនួនរឿងក្តីរបស់ អ.វ.ត.ក. ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៤*។

[5] ចំពោះឯកសារយោងជាមូលដ្ឋាន សូមមើល *កំណែប្រែ ៣១ នៃគម្រោងបញ្ចប់ផែនការនេះ*។

សំណុំរឿងនេះត្រូវបានបញ្ចប់ជាស្ថាពរ។ ជនជាប់ចោទបានទទួលមរណភាពនៅថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២០ នៅក្នុងមន្ទីរពេទ្យ ខណៈដែលកំពុងតែអនុវត្តទោសដាក់ពន្ធនាគារអស់មួយជីវិត។

៥. សំណុំរឿង ០០២ ត្រូវបានបំបែកទៅជាសវនាការចំនួនពីរ។ អង្គជំនុំជម្រះសាលាដំបូងបានចេញសាលក្រមនៅក្នុងសវនាការដំណាក់កាលទីមួយដែលមានឈ្មោះថា សំណុំរឿង ០០២/០១ នៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ ប្រឆាំងនឹង នួន ជា និង ខៀវ សំផន។ ជនជាប់ចោទចំនួនពីរនាក់ទៀតនៅក្នុងរឿងក្ដីនេះ គឺ អៀង សារី បានទទួលមរណភាពនៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣ និង អៀង ធីរិទ្ធ បានទទួលមរណភាពនៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៥ ហេតុដូចនេះ កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងពួកគេត្រូវបានរំលត់។ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ខៀវ សំផន និង នួន ជា មានពិរុទ្ធភាពពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ខែធ្នូ ឆ្នាំ១៩៧៧ នឹងត្រូវបានផ្តន្ទាទោសម្នាក់ៗឲ្យជាប់ពន្ធនាគារអស់មួយជីវិត។ ដំណើរការនីតិវិធីបណ្ដឹងសាទុក្ខ ក្នុងសំណុំរឿងនេះត្រូវបានបញ្ចប់នៅថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ដោយមានការប្រកាសសាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ។ អង្គជំនុំជម្រះបានតម្កល់សាលក្រមសម្រេចផ្តន្ទាទោសអស់មួយជីវិតលើជនជាប់ចោទទាំងពីរ។

៦. ការជំនុំជម្រះវគ្គទីពីរនៅក្នុងរឿងក្ដីនេះ ដែលមានឈ្មោះថា សំណុំរឿង ០០២/០២ បានផ្តោតលើជម្រើសតំណាងបទចោទមួយចំនួនដែលនៅសល់ប្រឆាំងនឹងជនជាប់ចោទ នួន ជា និង ខៀវ សំផន។ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្ដីសង្ខេបផ្ទាល់មាត់នៃសំអាងហេតុ និងផ្នែកសេចក្ដីសម្រេចរបស់សាលក្រមនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ និងបានចេញសាលក្រមរបស់ខ្លួនទាំង ៣ ភាសាផ្លូវការ នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩។ អង្គជំនុំជម្រះ បានរកឃើញថា ខៀវ សំផន និង នួន ជា មានពិរុទ្ធភាពពីបទប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ហើយបានផ្តន្ទាទោសជនជាប់ចោទទាំងពីរដាក់ពន្ធនាគារអស់មួយជីវិត។

៧. នៅថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៩ នួន ជា បានទទួលមរណភាពក្នុងអាយុ៩៣ឆ្នាំ ខណៈដែលកំពុងទទួលការព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត។ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ចប់កិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខប្រឆាំងនឹងរូបគាត់នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៩ និងបានបញ្ជាក់ថា ពុំមានកិច្ចដំណើរការនីតិវិធីប្រឆាំងនឹង នួន ជា តទៅទៀតទេ។

៨. នៅថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ២០២២ អង្គជំនុំជម្រះតុលាការកំពូលបានប្រកាសសាលដីការបស់ខ្លួនលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០២ ដោយតម្កល់ការផ្តន្ទាទោសដាក់ពន្ធនាគារ ខៀវ សំផន អស់មួយជីវិតដោយអង្គជំនុំជម្រះសាលាដំបូង។ អង្គជំនុំជម្រះតុលាការកំពូលបានតម្កល់ការផ្តន្ទាទោស ខៀវ សំផន ដោយអង្គជំនុំជម្រះសាលាដំបូង ពីបទប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មសង្គ្រាម។ អង្គជំនុំជម្រះបានតម្កល់ការរកឃើញពិរុទ្ធភាពទាំងអស់ លើកលែងតែពិរុទ្ធភាពពីរដែលពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរកឃើញពិរុទ្ធភាពសាជាថ្មីពីបទជួយនិងជំរុញដល់ការសម្លាប់មនុស្សនៅតាមសហករណ៍ ការដ្ឋាន និងមន្ទីរសន្តិសុខចំពោះទម្រង់នៃការទទួលខុសត្រូវនៃសហឧក្រិដ្ឋកម្មរួម។ ជាងនេះទៀត អង្គជំនុំជម្រះបានទទួលយកបណ្តឹងសាទុក្ខទាំងស្រុងរបស់សហព្រះរាជអាជ្ញា និងបានសម្រេចបញ្ចូលការរកឃើញពិរុទ្ធភាពចំពោះឧក្រិដ្ឋកម្មពាក់ព័ន្ធនឹងការបង្ខំឲ្យរួមភេទចំពោះជនរងគ្រោះជាបុរស នៅក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ អត្ថបទទាំងមូលនៃសាលដីកាត្រូវបានដាក់នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២ ជាភាសាខ្មែរ និងអង់គ្លេស[6]។ នេះជាការបញ្ចប់កិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២។

៩. **សំណុំរឿង ០០៣**៖ នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយចំនួនពីរដាច់ដោយឡែកពីគ្នា និងផ្ទុយគ្នា ក្នុងសំណុំរឿង ០០៣ ប្រឆាំង មាស មុត។ នៅថ្ងៃទី១៧

[6] សំណៅជាភាសាបារាំងនៃសាលក្រម គ្រោងនឹងដាក់នៅក្នុងត្រីមាសទីមួយ ឆ្នាំ២០២៣។

ខែធ្នូ ឆ្នាំ២០២១ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ថា "ដោយសារពុំមានដីកាបញ្ជូនរឿងទៅជំនុំជម្រះស្ថាពរ និងដែលអាចអនុវត្តបាន សំណុំរឿង ០០៣ ត្រូវបានបញ្ចប់"។ សំណុំរឿង ០០៣ ត្រូវបានបោះត្រា និងដាក់បញ្ចូលទៅក្នុងបណ្ណសារ តាមរយៈដីកាតុលាការ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២១ ដូច្នេះ វាជាការបញ្ចប់កិច្ចដំណើរការនីតិវិធីតាមផ្លូវតុលាការនៅក្នុងសំណុំរឿងនេះ។

១០. **សំណុំរឿង ០០៤៖** នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយពីរដាច់ដោយឡែកពីគ្នា និងផ្ទុយគ្នា ក្នុងសំណុំរឿង ០០៤ ប្រឆាំងនឹង យឹម ទិត្យ។ នៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ថា "ដោយសារពុំមានដីកាបញ្ជូនរឿងទៅជំនុំជម្រះស្ថាពរ និងដែលអាចអនុវត្តបាន សំណុំរឿង ០០៤ ត្រូវបានបញ្ចប់"។ សំណុំរឿង ០០៤ ត្រូវបានបោះត្រា និងដាក់បញ្ចូលទៅក្នុងបណ្ណសារតាមរយៈដីកាតុលាការ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១ ដូច្នេះ វាជាការបញ្ចប់កិច្ចដំណើរការនីតិវិធីតាមផ្លូវតុលាការនៅក្នុងសំណុំរឿងនេះ។

១១. **សំណុំរឿង ០០៤/០១៖** នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយ ដោយមានសំអាងហេតុលើកលែងចោទប្រកាន់សំណុំរឿង ០០៤/០១ ប្រឆាំងនឹង អ៊ឹម ចែម សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់បណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ នៅចំពោះមុខអង្គបុរេជំនុំជម្រះ។ នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ អង្គបុរេជំនុំជម្រះបានសម្រេចលើបណ្តឹងឧទ្ធរណ៍ ដោយប្រកាសជាអាទិ៍ថា សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតដែលថា អង្គជំនុំជម្រះវិសាមញ្ញមិនមានយុត្តាធិការលើ អ៊ឹម ចែម ចាត់ទុកជាបានការ ដែលជាការបញ្ចប់ដំណើរការនីតិវិធីតុលាការនៅក្នុងសំណុំរឿងនេះ។

១២. **សំណុំរឿង ០០៤/០២៖** នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយពីរដាច់ដោយឡែកពីគ្នា និងផ្ទុយគ្នា នៅក្នុងសំណុំរឿង ០០៤/០២ ប្រឆាំងនឹង អោ អាន ។ នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ថា "ដោយសារពុំមានដីកាបញ្ជូនរឿងទៅជំនុំជម្រះស្ថាពរ និងដែលអាចអនុវត្តបាន សំណុំរឿងប្រឆាំងនឹង អោ អាន ត្រូវ បានបញ្ចប់នៅចំពោះមុខ អ.វ.ត.ក."។ សំណុំរឿង ០០៤/០២ ត្រូវបានបោះត្រា និងដាក់បញ្ចូលទៅក្នុងបណ្ណសារតាមរយៈដីកាតុលាការ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២០ ដូច្នេះ វាជាការបញ្ចប់កិច្ចដំណើរការនីតិវិធីតាមផ្លូវតុលាការនៅក្នុងសំណុំរឿងនេះ។

## III. សំណុំរឿងបច្ចុប្បន្ន

១៣. នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២២ អង្គជំនុំជម្រះតុលាការកំពូល បានបង្គាប់ឱ្យសហព្រះរាជអាជ្ញាផ្តួចផ្តើម និងអនុវត្តការអនុវត្តទោសរបស់ ខៀវ សំផន (សូមមើល កថាខណ្ឌ ៨ ខាងលើ) ស្របតាមវិធាន ១១៣ នៃវិធានផ្ទៃក្នុង និងក្នុងកិច្ចសហការជាមួយអាជ្ញាធរជាតិ[7]។

១៤. អង្គជំនុំជម្រះក៏ទទួលបានសំណើចំនួនពីរផងដែរ ពាក់ព័ន្ធនឹងការធ្វើចំណាត់ប្រភេទឯកសារឡើងវិញ នៅក្នុងសំណុំរឿង ០០២ និងសំណុំរឿង ០០៤/០២[8]។ អង្គជំនុំជម្រះនឹងចេញសេចក្តីសម្រេចនៅក្នុងពេលវេលាសមស្រប។

## IV. វិធានការដែលអាចជួយបញ្ចប់កិច្ចដំណើរការនីតិវិធីបានឆាប់រហ័ស

១៥. បន្ទាប់ពីរាជរដ្ឋាភិបាលកម្ពុជាបានបង្ហាញនូវការគាំទ្រឡើងមក មហាសន្និបាតអង្គការសហប្រជាជាតិ នៅក្នុងខែធ្នូ ឆ្នាំ២០២១ បានអនុញ្ញាតឲ្យអគ្គលេខាធិការសម្រេចកំណត់ទឹកប្រាក់ចំនួនមិនលើស ៧ លាន

---

[7] សំណុំរឿង ០០២/១៩-០៩-២០០៧-អវតក/អជតក (*ឯកសារ F77/1/1*)។ នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៣ សហព្រះរាជអាជ្ញាបានផ្តួចផ្តើមដំណើរការផ្ទេរការនៃការផ្ទេរទណ្ឌិត ដោយមានសំណើមួយទៅកាន់នាយកដ្ឋានពន្ធនាគារកម្ពុជា ស្នើសុំឱ្យផ្ទេរទណ្ឌិតទៅពន្ធនាគារជាតិ។ សូមមើល សំណុំរឿង ០០២/១៩-០៩-២០០៧-អវតក/អជតក (*ឯកសារ F80, F81, F82*)។

[8] សំណុំរឿង ០០២/១៩-០៩-២០០៧-អវតក/អជតក (*ឯកសារ F71*)។ សំណុំរឿង ០០៤/០២/១៩-០៥-២០២០-អវតក/អជតក (០៤) (*ឯកសារ E004/2/7*)។

ដុល្លារ ក្នុងលក្ខណៈជាវិធានការពិសេស ដើម្បីបន្ថែមបង្គ្រប់ធនធានថវិកាស្ម័គ្រចិត្តរបស់ភាគីអន្តរជាតិនៃអង្គជំនុំជម្រះវិសាមញ្ញ សម្រាប់រយៈពេលគិតចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២។ សកម្មភាពទាន់ពេលវេលានេះបានជួយសម្រួលយ៉ាងច្រើន ដល់ប្រតិបត្តិការនៅអង្គជំនុំជម្រះវិសាមញ្ញ មិនឲ្យរអាក់រអួលក្នុងអំឡុងប្រាំបួនខែនៅឆ្នាំ២០២២ ដោយបើកឱកាសឱ្យមានការអង្គាសថវិកាស្ម័គ្រចិត្តបន្តទៀត។ ជាងនេះទៀត ការសម្រេចរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការផ្តល់វិភាគទានដោយផ្ទាល់ចំនួន ៣,៤ លានដុល្លារ ដើម្បីចំណាយទៅលើប្រាក់បៀវត្សបុគ្គលិកជាតិ ១០ខែ ដំបូង ក៏ដូចជាចំណាយប្រតិបត្តិការសម្រាប់ឆ្នាំ២០២២ គឺជាវិធានការដ៏សំខាន់ដែលជួយដល់ប្រតិបត្តិការ ដែលកំពុងដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញ។ ដោយរួមបញ្ចូលគ្នាបែបនេះ វិធានការទាំងនេះ ធានាថា ទំហំការងារបច្ចុប្បន្នរបស់អង្គជំនុំជម្រះវិសាមញ្ញ បន្តទទួលបាននូវការយកចិត្តទុកដាក់ និង ថវិកាចាំបាច់ជាបន្តទៀត។ វិភាគទានស្ម័គ្រចិត្តដែលទទួលបាន សម្រាប់ឆ្នាំ២០២២ មានចំនួន ៣,៥ លានដុល្លារ សម្រាប់ភាគីអន្តរជាតិ និងចំនួន ០,៥ លានដុល្លារសម្រាប់ភាគីជាតិ។ ថវិកានេះដើម្បីបង្គ្រប់តាមតម្រូវការថវិកាសម្រាប់ឆ្នាំ២០២២ ចំនួន ៨,៤ លានដុល្លារសម្រាប់ភាគីអន្តរជាតិ និង ៤,៣ លានដុល្លារសម្រាប់ភាគីជាតិ[9]។

## V. សេចក្តីសន្និដ្ឋាន

១៦. សម្រាប់ឆ្នាំ២០២២ ព្រឹត្តិការណ៍សំខាន់មួយត្រូវបានរំពឹងទុក គឺការចេញសាលដីកាជាលាយលក្ខណ៍អក្សរ ក្នុងសំណុំរឿង០០២/០២ ដោយអង្គជំនុំជម្រះតុលាការកំពូល នៅត្រីមាសទី៤។

១៧. ក្នុងឆ្នាំ២០២៣ អង្គជំនុំជម្រះវិសាមញ្ញ នឹងចាប់ផ្តើមមុខងារសេសសល់ ស្របតាមកិច្ចព្រមព្រៀងបន្ថែមទៅលើកិច្ចព្រមព្រៀងស្តីពី អ.វ.ត.ក.[10]។

[9] តួលេខថវិកាសម្រាប់ឆ្នាំ២០២១-២០២២ ត្រូវបានគាំទ្រដោយក្រុមបណ្តាប្រទេសដែលមានចំណាប់អារម្មណ៍ នៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២១។

[10] សូមមើលកថាខណ្ឌ ១។